# ការស្រាវជ្រាវឯកសារ

## LA RECHERCHE DOCUMENTAIRE

Conscient ou inconscient, tout les êtres vivants ont besoin de faire la recherche. C’est une pense bête si on dit qu’on n’a pas besoin de faire des recherches parce qu’on sait tout ! Chaque personne a sa façon pour faire des recherches. On ne peut jamais imposer une méthodologie idéale qui est valable pour toujours. Il en est de même pour le résultat de la recherche, c’est comme à l’époque avant la renaissance, tout le monde croyait que la terre était plate et si on disait le contraire, on serait condamné à mort ou on serait considéré comme fou. L’article suivant ne traite pas le problème sus-cité mais vous montrera plutôt quelques pistes afin de vous donner des idées sur la recherche documentaire sur le net ou à la bibliothèque.

ការស្រាវជ្រាវឯកសារគឺជាអធិក្រមមួយដែលក្តោបបញ្ចូលនូវរាល់សកម្មភាពផ្សេងៗនៃការងារដែលទាមទារឱ្យស្វែងរកនូវឯកសារ ទោះបីជាស្ថិតនៅក្នុងក្របខ័ណ្ឌការងារ ជារឿងផ្ទាល់ខ្លួនឬក៏ក្នុងការសិក្សាក្តី។

យើងដឹងហើយថា វឌ្ឍនភាពនៃវិទ្យាសាស្ត្រដែលគេចាត់ទុកជាស្នាដៃរួមព័ត៌មានដែលទាក់ទងអំពីការរីកចម្រើនទាំងនោះត្រូវបានគេប្រាស្រ័យទាក់ទងគ្នារវាងក្រុមអ្នកស្រាវជ្រាវ ដោយប្រើគ្រប់យុទ្ធវិធីប្រយោជន៍ក្នុងការផ្សព្វផ្សាយព័ត៌មានទាំងនោះឱ្យបានលឿន ព្រមទាំងមានលក្ខណៈពេញលេញផង។

ទោះបីវាគ្រាន់តែជារបៀបពិសោធន៍ដែលគេប្រើប្រាស់ ជាការសង្កេតជាការសាកល្បងដែលគ្មានទទួលផ្លែផ្កាដូចដែលបានគ្រោងទុកក៏ដោយក៏ចំណេះដឹងទាំងនោះត្រូវបានគេចាត់ទុកជាមធ្យោបាយមួយសម្រាប់អ្នកស្រាវជ្រាវ វាជាឱសថដ៏មានតម្លៃមួយនៅក្នុងផ្នែកវិទ្យាសាស្ត្រសង្កេត និងជាចំណុចចាប់ផ្តើមមួយសម្រាប់វិស្វករ និងអ្នកបច្ចេកទេស។



គ្មាននរណាម្នាក់ដែលល្អឥតខ្ចោះនោះទេ នេះគឺជាសុភាសិតមាសមួយដែលមានតម្លៃជានិរន្ត។ អ្វីមួយដែលខ្ញុំដឹង គឺខ្ញុំមិនចេះអ្វីទាំងអស់ នេះគឺជាសម្តីរបស់ទស្សនវិទូក្រិក ៤៦៩-៣៩៩ មុនគ្រិះសករាជឈ្មោះសូក្រាត។ ពិតណាស់ហើយថាវាជាពាក្យសម្តីមួយដែលបញ្ជាក់ពីសាមញ្ញភាពរបស់គាត់ តែយើងក៏អាចយល់បានថា វាគឺជាពាក្យមួយដ៏ល្អសម្រាប់អប់រំទូន្មានដល់អស់មនុស្សផងទាំងពួងថា គ្មាននរណាដែលចេះដឹងគ្រប់សព្វអស់នូវអ្វីៗដែលមាននៅក្នុងលោកយើងនេះទេ។ នៅក្នុងន័យនេះ លោកឡៅស៊ី អ្នកទស្សនវិទូចិននៅក្នុងកំឡុងឆ្នាំ ៤៧០-៥៩០ បានមានប្រសាសន៍ថា ទោះបីជាខ្ញុំមានវ័យចំណាស់នេះក៏ដោយ ក៏ខ្ញុំនៅតែសិក្សាស្រាវជ្រាវដែរ ហើយប្រសិនបើខ្ញុំជួបក្មេងអាយុប្រាំឆ្នាំម្នាក់ ហើយវាចេះអ្វីមួយដែលខ្ញុំមិនចេះ ខ្ញុំនឹងរៀនអំពីវា ហើយប្រសិនបើខ្ញុំជួបមនុស្សចាស់ជាងខ្ញុំ ហើយមានចំណេះដឹងតិចជាងខ្ញុំ ខ្ញុំនឹងបង្ហាត់បង្ហាញទៅគាត់នូវអ្វីដែលខ្ញុំដឹង។ ទាំងនេះ សបញ្ជាក់ឱ្យឃើញថា ការសិក្សាស្រាវជ្រាវ គឺត្រូវធ្វើរហូតលុះណាតែផុតរលត់ជីវិតរបស់មនុស្សម្នាក់ៗ។ ចំណេះដឹងនៅក្នុងសកលលោកនេះ ពិតជាធំទូលំទូលាយណាស់ ហើយគ្មាននរណាម្នាក់ដែលអាចចេះដឹងសព្វគ្រប់នូវចំណេះដឹងទាំងនោះទេ។ វាពិតជាការឆោតល្ងង់មួយ ប្រសិនបើអ្នកអះអាងថាខ្លួនចេះសព្វគ្រប់ មិនត្រូវការការស្រាវជ្រាវនោះ។ ផ្ទុយទៅវិញ គឺដោយសារការស្រាវជ្រាវ ការឆ្ងល់របស់មនុស្សនេះឯងហើយដែលធ្វើឱ្យសង្គមមនុស្សមានការរីកចម្រើនរហូតមកដល់សព្វថ្ងៃនេះ។

ដូចគ្នានេះដែរ យើងក៏អាចយល់បានថាការធ្វើឯកសារអ្វីមួយដើម្បីឱ្យឯកសារទាំងនោះមានតម្លៃ គឺគេត្រូវការអំណះអំណាង មានន័យថាតើការគិតរបស់យើងនោះ មានគេបានគិតហើយឬនៅ ហើយប្រសិនណាជាគេធ្លាប់បានគិតនិងផ្សាយរួចហើយនោះ នោះមានន័យថាគំនិតរបស់យើងមិនមែនជាគំនិតដែលថ្មីនោះទេ ពេលនោះ យើងត្រូវលើកបង្ហាញអំពីឈ្មោះរបស់អ្នកដែលមានគំនិតនោះមុនយើង ដើម្បីឱ្យការគិតរបស់យើងកាន់តែមានទម្ងន់និងមានតម្លៃ ព្រមទាំងដើម្បីចៀសវាងនូវការលួចចម្លងស្នាដៃរបស់គេផង។ កាលពីសម័យមុន ដើម្បីឱ្យអំណះអំណាងរបស់ខ្លួនកាន់តែមានប្រសិទ្ធិភាព គេច្រើនតែប្រើពាក្យថានេះគឺជាសង្ឃដិកា ឬជាពុទ្ធិដិកាជាដើម ពោលគឺដោយសារតែវិស័យសាសនាមានឥទ្ធិពលខ្លាំង ហើយខាងផ្នែកវិទ្យាសាស្ត្រមិនទាន់មានភាពរីកចម្រើនខ្លាំងផង។ នៅក្នុងបរិបទបច្ចុប្បន្ន អំណះអំណាងតាមបែបសាសនានៅតែត្រូវបានគេប្រើ តែការប្រើនេះមិនសូវ

ជាទូលំទូលាយដូចជាសម័យមុននោះទេ។ នៅក្នុងបរិបទបច្ចុប្បន្ន ការរកអំណះអំណាងគឺច្រើនតែផ្តោតទៅលើអ្នកនិពន្ធ ឬអ្នកទស្សនៈវិទូធំៗទៅវិញ។

នៅក្នុងអត្ថបទនេះ យើងខ្ញុំសូមលើកយកបទពិសោធន៍របស់យើងខ្ញុំដែលជាចំណែកដ៏តូចមួយនៃចំណេះដឹងខាងការស្រាវជ្រាវមកបង្ហាញជូនទុកគ្រាន់ជាគំនិតសម្រាប់ពិចារណា។

តើយើងត្រូវធ្វើអ្វីខ្លះដើម្បីរកឯកសារដែលយើងចង់បាន?

តាមការពិត ការរកឯកសារវាមិនមានរបៀបរហូតដល់ច្រើនហួសប្រមាណដែលឱ្យយើងចងចាំមិនអស់នោះទេ។ នៅក្នុងអត្ថបទនេះយើងខ្ញុំសូមបង្ហាញជូននូវដំណាក់កាលមួយចំនួនដែលអ្នកឯកសារវិទូចង្អុលបង្ហាញប្រយោជន៍ដើម្បីធ្វើការស្រាវជ្រាវឯកសារមួយប្រកបដោយប្រសិទ្ធិភាពនិងឆ្លើយតបតាមតម្រូវការ។

ក. អានឯកសារ

ឧទាហរណ៍ យើងមានបទអត្ថាធិប្បាយទៅលើសិទ្ធិមនុស្សមួយដែលត្រូវធ្វើជាប្រញាប់ យើងអាចរកបានឯកសារទាំងនោះនៅតាមមជ្ឈមណ្ឌល



ឯកសារនានាដោយគ្មានបារម្ភ យើងត្រលប់មកផ្ទះវិញដោយមានឯកសារដែលទាក់ទងជាមួយប្រធានបទនោះពេញនៅក្នុងដៃ គឺចាប់តាំងពីសេចក្តីប្រកាសនៅឆ្នាំ ១៧៨៩ រហូតមកដល់របាយការណ៍នៃសន្និសញ្ញាលើកលែងទោសអន្តរជាតិ។ យើងបានទាញយកឯកសារនោះដែលមានទំហំរហូតទៅដល់ ២០ មេហ្គាប៊ីត ហើយឯកសារទាំងនោះរួមមាន ជាអត្ថបទ ជារូបភាព ជាខ្សែភាពយន្តជាដើម! នៅពេលនោះយើងគ្មានពេលសម្រាប់អានវាទាំងអស់បាននោះទេ ព្រោះថាបទអត្ថាធិប្បាយត្រូវធ្វើនៅថ្ងៃស្អែកនេះហើយ។ តើយើងត្រូវធ្វើ យ៉ាងណា?

ឆ្លើយទៅនឹងសំណួរនេះ យើងអាចនិយាយដោយឆ្លងតាមរយៈការសង្កេតរបស់យើងបានថា ការស្រាវជ្រាវគឺច្រើនតែធ្វើដោយការដើរប្រមូលយកនូវឯកសារដែលទាក់ទងទៅនឹងអ្វីដែលត្រូវទៅតាមប្រធានបទរបស់ខ្លួន ហើយឯកសារដែលរកបានទាំងនោះច្រើនតែត្រូវបានគេគរទុកវាជាជុំ ព្រោះថាយើងគ្មានពេលសម្រាប់អានវានោះទេ រួចនៅទីបំផុតដំណើរផ្សងព្រេងរបស់ឯកសារទាំងនោះគឺច្រើនតែត្រូវបញ្ចប់នៅក្នុងធុងសំរាម។ ដូចគ្នានេះដែរ ចំពោះឯកសារនៅលើម៉ាស៊ីកុំព្យូទ័រ យើងគ្រាន់តែអាចសន្សំសំចៃដើមឈើដែលត្រូវកាប់សម្រាប់មកធ្វើក្រដាសប៉ុណ្ណោះឯចំណែកពេលវេលាសម្រាប់អានវា គឺត្រូវប្រើពេលវេលាដូចដែលការអានឯកសារក្រដាសដែរ។ ដូច្នេះប្រការដែលចាំបាច់ត្រូវអានឯកសារដែលរកបាននោះឱ្យលឿនតាមដែលអាចធ្វើបានជាជាងនឹងការដើរស្វែងរកឯកសារដែលទាក់ទងទៅនឹងប្រធានបទឱ្យបានច្រើនជាអតិបរមានោះ។ ត្រូវចងចាំថាឯកសារភាគច្រើនដែលផ្ទុកនូវព័ត៌មានពិតប្រាកដនិងត្រឹមត្រូវនោះគឺច្រើនតែនៅខាងក្រៅប្រព័ន្ធអ៊ីនធឺណែត ដូចជា : នៅក្នុងវិជ្ជាសមោធាន នៅក្នុងសៀវភៅច្បាប់ដើម នៅក្នុងសន្និសញ្ញា ឬនៅក្នុងប្រវត្តិនៃទស្សនៈវិជ្ជាជាដើម។

ខ. រៀបចំឯកសារ

យើងរីករាយព្រោះថាមានឯកសារសំខាន់ៗជាច្រើនដែលយើងរកបានពីទំព័រដ្ឋាននានា ហើយយើងចេះតែថតចម្លងឯកសារទាំងនោះជាបន្តបន្ទាប់ រហូតទៅដល់ដំណាក់កាលមួយដែលឯកសារអាស្យាណូរបស់យើងកាន់តែមានចំនួនច្រើនឡើងៗដែលផ្ទុកនៅក្នុងថាសរឹងនៃម៉ាស៊ីនកុំព្យូទ័ររបស់យើង។ ឯកសារទាំងនោះ ដែលមានទម្រង់ជា html, gif, txt, doc, mov, mp3, zip, exe, wma ជាដើមនោះកាន់តែច្របូកច្របល់គ្នា និងកាន់តែមានចំនួនច្រើនឡើងៗ ដែលធ្វើឱ្យយើងឈឺក្បាលនៅពេលដែលត្រូវការរកវា ឬមើលវាម្តងៗ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ក៏ដូចជាដើម្បីជួយសម្រួលក្នុងការរៀបចំឯកសារដែលយកមកពីទំព័រអ៊ីនធឺណែត នៅបច្ចុប្បន្ននេះមានកម្មវិធីមួយឈ្មោះថា HTTrack ដែលជាកម្មវិធីសេរីមួយដែលយើងអាចរកបាននៅលើបណ្តាញអ៊ីនធឺណែត ហើយកម្មវិធីនេះអាចជួយឱ្យយើងទាញ

យកគេហទំព័ររបស់ស្ថាប័នណាមួយយកមកដាក់នៅលើថាសរឹងរបស់យើងដោយរក្សាបាននូវរាល់រចនាសម្ព័ន្ធរបស់ទំព័រដ្ឋាននោះប្រយោជន៍ដើម្បីឱ្យយើងអាចមើលទំព័រដ្ឋាននោះទៅថ្ងៃក្រោយដោយមិនចាំបាច់ភ្ជាប់ប្រព័ន្ធអ៊ីនធឺណែតនោះឡើយ។

កាលណាយើងរកបានឯកសារនៅលើទំព័រអ៊ីនធឺណែតភ្លាម ដើម្បីចៀសវាងការភ្លេចភ្លាំងមិនដឹងថា ឯកសារនោះនៅឯណាយើងត្រូវបោះពុម្ពវាភ្លាមដោយមិនត្រូវរង់ចាំនោះឡើយ រួចយកវាទៅរៀបចំទុកដាក់នៅក្នុងដុំឯកសារដែលមានខ្លឹមសារដូចគ្នាឱ្យបានត្រឹមត្រូវ ដូចជាឯកសារថតចម្លងផ្សេងៗទៀតដែរ។

គ. ចេះវិភាគឯកសារទាំងនោះ




ដូចដែលយើងបានដឹងរួចមកហើយថា ឯកសារនៅលើទំព័រអ៊ីនធឺណែតគឺសុទ្ធសឹងតែជាឯកសារដែលមានការប្តូរផ្លាស់គ្រប់ពេលវេលា។ ត្រូវចេះត្រួតពិនិត្យព័ត៌មាននៅក្នុងឯកសារទាំងនោះ ត្រូវចេះប្រៀបធៀប និងបន្ថែមព័ត៌មានដ៏ទៃទៀតដែលបានមកពីប្រភពផ្សេងៗ ដូចជាយកចេញពីសៀវភៅវិជ្ជាសមោធានជាដើម ។ មិនត្រូវទុកចិត្តទាំងស្រុងចំពោះព័ត៌មានដែលផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណែតនោះទេ ព្រោះថាមានព័ត៌មានមួយចំនួនដែលនៅលើទំព័រអ៊ីនធឺណែត វាជាព័ត៌មានដែលមិនត្រឹមត្រូវ និងអនាធិបតេយ្យ។ ត្រូវចងចាំថា នរណាក៏អាចបង្កើតទំព័រដ្ឋាននៅលើបណ្តាញអ៊ីនធឺណែតដែរ។ ហើយចំពោះព័ត៌មានមួយចំនួនទៀតដែលត្រឹមត្រូវយកជាការបាននោះ ក៏សុទ្ធសឹងតែជាព័ត៌មានមិនពេញលេញ ឬក៏គ្រាន់តែជាសេចក្តីសន្និដ្ឋានប៉ុណ្ណោះ ពោលគឺវាមិនទាន់ពិតប្រាកដនៅឡើយ។ ត្រូវចងចាំថាអ្នកនិពន្ធគេត្រូវការទ្រទ្រង់ជីវិតរបស់គេដែរ ដូច្នេះរាល់ឯកសារដែលមានលក្ខណៈត្រឹមត្រូវ ពេញលេញគឺវាស្ថិតនៅក្នុងសៀវភៅដែលយើងត្រូវតែចំណាយលុយទិញវា ឬប្រសិនបើវាស្ថិតនៅលើទំព័រអ៊ីនធឺណែតវិញនោះ ក៏យើងត្រូវទិញវាដែរ ដោយទិញវាតាមរយៈប័ណ្ណធនាគារជាដើម។ នៅលើបណ្តាញអ៊ីនធឺណែត យើងក៏អាចរកបានសារណា និក្ខេបបទ ឬក៏សេចក្តីអត្ថាធិប្បាយផ្សេងៗរបស់និស្សិតដែលមិនទាន់បានការពារហើយកំពុងតែរង់ចាំការដាក់ពិន្ទុពីសាស្ត្រាចារ្យ ឬក៏ក្រុមគណៈមេប្រយោគ តែត្រូវចាំថាភាពយកជាការបានរបស់ឯកសារទាំងនោះ វាមានតម្លៃនៅត្រឹមកម្រិតណាមួយប៉ុណ្ណោះ។ ដូច្នេះអ្វីដែលយើងត្រូវធ្វើ គឺត្រូវចេះស្វែងយល់អំពីអត្តសញ្ញាណរបស់អ្នកនិពន្ធ ប្រយោជន៍ក្នុងការធ្វើឱ្យឯកសារយោងរបស់យើងកាន់តែមានតម្លៃ។

ឃ. ត្រូវចេះជ្រើសរើសឯកសារណាដែលត្រូវលុបចោល

ការរក្សាទុកឯកសារវាជាការល្អមួយនោះហើយ តែយើងក៏មិនអាចទុកវាបានច្រើននោះដែរ លើកលែងតែយើងចង់ក្លាយខ្លួនទៅជាអ្នកឯកសារវិទូ ឬមួយក៏យើងមានថាសរឹងនៅក្នុងម៉ាស៊ីនកុំព្យូទ័រដែលអាចផ្ទុកឯកសារមិនចេះពេញ ដូច្នេះយើងត្រូវដឹងថាឯកសារណាដែលយើងត្រូវលុបវាចោល និងឯកសារណាទៀតដែលយើងត្រូវរក្សាទុកវា។ យើងត្រូវលុបចោលនូវរាល់ឯកសារណាដែលលែងមានប្រយោជន៍សម្រាប់យើង នៅពេលដែលយើងបញ្ចប់ការងារ។ ប្រសិនបើយើងពិតជាត្រូវការនូវរាល់ឯកសារដែលយើងបានប្រើប្រាស់ហើយនោះមែន យើងអាចរក្សាវាដោយចម្លងវាជាទម្រង់ txt ព្រោះថានៅក្នុងទម្រង់នេះ ឯកសារមិនប្រើប្រាស់ទំហំធំនៅលើថាសរឹងដូចជាបណ្តាឯកសារដែលស្ថិតនៅក្នុងទម្រង់ផ្សេងៗទៀតនោះទេ។ ប្រសិនបើយើងបោះពុម្ពឯកសារទាំងនោះ យើងត្រូវចេះជ្រើសយកតែអ្វីដែលសំខាន់ៗដោយរក្សាទុកវាឱ្យបានល្អ ព្រមទាំងដាក់ចំណុចយោងឱ្យបានច្បាស់ប្រយោជន៍ ឱ្យងាយស្រួលក្នុងការស្វែងរកឯកសារទាំងនោះទៅថ្ងៃក្រោយ។ ហើយចំពោះអ្វីដែលមិនសំខាន់ ត្រូវលុបវាចោលដោយរក្សាទុកតែអ្វីដែលមានតម្លៃទាំងខាងផ្នែកឯកសារ ក៏ដូចជាខាងទស្សនៈវិជ្ជាដែលអាចយកវាមកប្រើប្រាស់បានទោះជាក្រោយពេលបីឬបួនឆ្នាំទៀតក៏ដោយ។

អត្ថបទ : សំអោ អង្គារតន៍